# លោកជំទាវ ជូ ប៊ុនអេង បានអនុញ្ញាតឲ្យតំណាងស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសំណេះសំណាលស្វែងយល់អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា




(ភ្នំពេញ) កាលពីព្រឹកថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ នៅសាលប្រជុំអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស(គ.ជ.ប.ជ) **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានអនុញ្ញាតឲ្យតំណាង ស្ថានទូតសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសំណេះសំណាល ពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ស្វែងយល់អំពីការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។

ជាកិច្ចចាប់ផ្តើម **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅ និងបានធ្វើការណែនាំខ្លួន និងសមាសភាពដែលបានអញ្ជើញចូលរួមនាពេលនេះ បន្ទាប់មកខាងតំណាងស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ធ្វើការណែនាំខ្លួន សមាសភាពតួនាទីភារកិច្ចផងដែរ។ **លោកជំទាវ** មានប្រសាសន៍ទាក់ទងទៅនឹងសកម្មភាពការងារចម្បងៗ និងការងារប្រចាំថ្ងៃរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ។ **លោកជំទាវ** បានបន្ថែមទៀតថា ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មិនអាចធ្វើតែម្នាក់ឯងបានទេ ត្រូវទាមទារឲ្យមានការសហការគ្នាពីគ្រប់មជ្ឈដ្ឋាន គ្រប់ទិសទីពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូនានា និងមានការសហការគ្នារវាងប្រទេស និងប្រទេសនៅក្នុងតំបន់ ក៏ដូចជានៅលើសកលលោក ដើម្បីរួមគ្នាបង្ការទប់ស្កាត់នូវអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារ។ **លោកជំទាវ** មានប្រសាសន៍ដោយសង្ខេបអំពីរចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិរហូតដល់មូលដ្ឋាន និងក្រុមការងារទាំងប្រាំមួយ ដែលបានចូលរួមសហការពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន យើងមានគោលនយោបាយជាតិ និងយុទ្ធសាស្ត្រ នៃការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សនៅកម្ពុជា។




មតិលោក Ben Jamin Skinner (Visiting Scholar) លោកបានសំដែងការអបអរសាទរចំពោះចំណាត់ថ្នាក់ទាក់ទងការជួញដូរមនុស្សនៅកម្ពុជា ដែលបានទទួលនូវលទ្ធផលល្អប្រសើរ បើប្រៀបធៀបទៅនឹងនៅក្នុងតំបន់មួយចំនួន។ វាជាការចាំបាច់ណាស់ក្នុងការសហការគ្នា ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារប៉ុន្តែយើងសង្កេតឃើញថា ការជួញដូរមនុស្សមានការថយចុះជាលំដាប់គួរឲ្យកត់សម្គាល់។ ដោយឡែកនៅប្រទេសកម្ពុជាវិញ បានទទួលចំណាត់ថ្នាក់លេខពីរ នៃការវាយតម្លៃពីសហរដ្ឋអាមេរិក តែវាមិនទាន់បានល្អនៅឡើយយើងចង់បានចំណាត់ថ្នាក់លេខមួយ។ លោក Ben Jamin Skinner បានមានមតិទាក់ទងទៅនឹងការជួញដូរមនុស្ស ឲ្យមានការចូលរួមពីបណ្តាវិស័យឯកជន អ្នកជំនួញ អ្នកធ្វើអាជីវកម្មផ្សេងៗ ត្រូវធ្វើការទាក់ទាញដើម្បីឲ្យពួកគាត់ចូលរួមចំណែក ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពីព្រោះវិស័យឯកជន អ្នកធ្វើអាជីវកម្ម អ្នកជំនួញ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការចូលរួមគាំទ្រដើម្បីធ្វើការបង្ការ ទប់ស្កាត់ នូវអំពើជួញដូរមនុស្ស ការ

រំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្មជាដើម។ លោក Ben Jamin Skinner មានមតិទាក់ទងទៅនឹងការបោះឆ្នោត ជ្រើសរើសប្រធានាធិបតីសហរដ្ឋអាមេរិក នាពេលខាងមុខនេះ ប្រសិនបើលោកស្រី **ហ៊ីឡារី គ្លីនតុន** នៃគណៈបក្សប្រជាធិបតេយ្យជាប់ឆ្នោតជាប្រធានាធិបតី លោកស្រីនឹងផ្តោតសំខាន់ទៅលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាការងារអទិភាព និងជាពិសេសប្រទេសកម្ពុជា លោកស្រីធ្លាប់បានមកធ្វើទស្សនៈកិច្ចរួចមកហើយ ហើយលោកស្រីធ្លាប់បានជួបជាមួយជនរងគ្រោះ ដោយអំពើជួញដូរមនុស្សផងដែរ។ ចុងបញ្ចប់លោក Ben Jamin Skinner បានសួរសំនួរថា **តើរាជរដ្ឋាភិបាលកម្ពុជាមានគោលបំណង ផ្តោតទៅលើវិស័យឯកជន អ្នកវិនិយោគ អ្នកជំនួញ មកចូលរួមសហការក្នុងការងារ ទប់ស្កាត់ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែរទេ?**

**លោកជំទាវ ជូ ប៊ុនអេង** មានប្រសាសន៍ទាក់ទងទៅនឹងការបោះឆ្នោត ជ្រើសរើសប្រធានាធិបតីសហរដ្ឋអាមេរិក បើលោកស្រី **ហ៊ីឡារី គ្លីនតុន** ជាប់ជាប្រធានាធិបតី ខ្ញុំមានការសប្បាយរីករាយជាខ្លាំង មិនមែនខ្ញុំជាស្ត្រីដូចគ្នាទេតែវាជាការពាក់ព័ន្ធទៅនឹងមនុស្សជាតិ។ **លោកជំទាវ** មានប្រសាសន៍ឆ្លើយតបនឹងសំនួររបស់លោក Ben Jamin Skinner ថារាជរដ្ឋាភិបាលកម្ពុជាផ្តោតសំខាន់ទៅលើការជួញដូរមនុស្ស ដែលមានការចូលរួមសហការពីបណ្តាក្រសួង ស្ថាប័ន និងវិស័យឯកជនក្នុងការជួយជ្រោមជ្រែង គាំទ្រក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមណ្ឌលកំសាន្ត សម្រាប់មនុស្សចាស់ គឺមិនត្រូវបានអនុញ្ញាតិឲ្យយុវវ័យអាយុក្រោមដប់ប្រាំបីឆ្នាំចូលឡើយ ហើយបានធ្វើកិច្ចសន្យាជាមួយសណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត ខារ៉ាអូខេ ម៉ាស្សា-កោសជប់ និងកន្លែងកំសាន្តនានាមួយចំនួនទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតិ ឬបង្កប់ លួចលាក់សេវាផ្លូវភេទ អំពើពេស្យាចារលើស្ត្រី និងកុមារនៅក្នុងនោះឡើយ ហើយបានប្រគល់ភារកិច្ចទាំងអស់នេះឲ្យក្រសួងទេសចរណ៍ជាអ្នកគ្រប់គ្រង នេះគឺជាការចូលរួមពីវិស័យឯកជន។ **លោកជំទាវ** បានបន្តថាការទប់ស្កាត់អំពើជួញដូរមនុស្ស ត្រូវបានក្រសួងអប់រំ យុវជន និងកីឡា បញ្ចូលទៅក្នុងកម្មវិធីអប់រំ សិក្សា នៅតាមបណ្តាគ្រឹះស្ថានសិក្សានានាចាប់ពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់មធ្យមសិក្សាផងដែរ។




ចុងបញ្ចប់ នៃពិធីសំណេះសំណាល លោក Ben Jamin Skinner មានមតិថ្លែងអំណរគុណចំពោះ **លោកជំទាវ** និងក្រុមការងារ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ដ) ដែលបានចំណាយពេលវេលាដ៏មានតំលៃក្នុងការជួបសំណេះសំណាល និងផ្លាស់ប្តូរនូវបទពិសោធន៍ការងារពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ និងគោរពជូនពរ**លោកជំទាវ** និងក្រុមការងារមានសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច។ បន្ទាប់មក **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មានប្រសាសន៍ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក Ben Jamin Skinner និងក្រុមការងារតំណាងស្ថានទូតសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានចំណាយពេលវេលាមានតំលៃមកជួបពិភាក្សា សំណេះសំណាល និងផ្តល់បទពិសោធន៍ដ៏មានអត្ថន័យទៅវិញទៅមក។ **លោកជំទាវ** បានជូនពរចំពោះលោក Ben Jamin Skinner និងក្រុមការងារទទួលបានជោគជ័យគ្រប់ភារកិច្ច។